នស/រកត/១១២៤/ ១៤១២

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិដឹកនាំអនុវត្ត
## កម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ដែលសរសេរជាអក្សរកាត់ថា **ផ.ក.អ.** ជាយន្តការដឹកនាំ សម្របសម្រួល និងអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ក្នុងគោលដៅផ្តល់ដីក្រោមទម្រង់សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានទីលំនៅសម្រាប់សង់លំនៅឋាននិងខ្វះដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងគាំទ្រគម្រោងអភិវឌ្ឍសហគមន៍ ព្រមទាំងការពារព្រៃនៅជិតទីតាំងផ្តល់ដីប្រកបដោយចីរភាព។

## ជំពូកទី២

## ភារកិច្ចរបស់ ផ.ក.អ.

**មាត្រា២ .-**

**ផ.ក.អ.** មានភារកិច្ចដូចតទៅ៖

- កំណត់និងដាក់ចេញនូវគោលនយោបាយចំពោះកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព
- ពិនិត្យនិងកំណត់ទីតាំងដីដែលត្រូវជ្រើសរើសដាក់បញ្ចូលក្នុងកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព
- ពិនិត្យនិងសម្រេចលើបុគ្គលមានសិទ្ធិទទួលបានដីក្រោមទម្រង់សម្បទានដីសង្គមកិច្ច
- ពិនិត្យនិងសម្រេចលើផែនការអភិវឌ្ឍនៅទីតាំងនិងនៅជិតទីតាំងកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ដោយរួមទាំងគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានាទាំងនៅទីតាំងកម្មវិធីផ្តល់ដីនិងតំបន់តភ្ជាប់
- ពិនិត្យនិងសម្រេចលើសំណើលុបចោលការសម្រេចឬកែសម្រួលផែនការប្រើប្រាស់និងបែងចែកដី ព្រមទាំងដកហូតដីពីបុគ្គលមានសិទ្ធិទទួលដី ដែលខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់និងប្រើប្រាស់ដី
- ពិនិត្យនិងសម្រេចលើគម្រោងថវិកាក្នុងការអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព
- ពិនិត្យនិងសម្រេចលើបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋពាក់ព័ន្ធកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព ក្រោមទម្រង់សម្បទានដីសង្គមកិច្ច
- សម្របសម្រួលនិងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងភាគីពាក់ព័ន្ធ ដែលមានបំណងចូលរួមគាំទ្រកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាព
- ផ្តល់ការតម្រង់ទិសលើការអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃដើម្បីរួមគ្នាអភិវឌ្ឍដោយចីរភាពឱ្យកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល។

# ជំពូកទី៣
# សមាសភាពរបស់ ថ.ក.អ.

**មាត្រា៣ .-**

**ថ.ក.អ.** មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រី | ប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| - ឥស្សរជនជាន់ខ្ពស់ ១រូប | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងអធិការកិច្ច | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | សមាជិក |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន សមាជិក
- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក
- អគ្គស្នងការនគរបាលជាតិ សមាជិក
- មេបញ្ជាការកងទ័ពជើងគោក សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- មេបញ្ជាការកងវិស្វកម្មតេជោ ហ៊ុន សែន សៀមរាប សមាជិក
- មេបញ្ជាការវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក។

សមាសភាពជាក់ស្តែងនៃ **ផ.ក.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ផ.ក.អ.** អាចមានសមាសភាពបន្ថែម ជាប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនជាន់ខ្ពស់ផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅនៃ ផ.ក.អ.

**មាត្រា៤ .-**

**ផ.ក.អ.** ត្រូវប្រជុំយ៉ាងតិចរៀងរាល់៦(ប្រាំមួយ)ខែម្តងឬប្រជុំវិសាមញ្ញតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ ប្រធាន **ផ.ក.អ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

តាមការអញ្ជើញរបស់ប្រធានឬតំណាងដែលទទួលបានការប្រគល់សិទ្ធិពីប្រធាន អនុប្រធាននិងសមាជិក **ផ.ក.អ.** ត្រូវចូលរួមប្រជុំឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមានឬមានធុរៈ។

**មាត្រា៥ .-**

**ផ.ក.អ.** ប្រើត្រារបស់គណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងារ។

**មាត្រា៦ .-**

**ផ.ក.អ.** អាចមានគណៈកម្មការជំនាញនិង/ឬក្រុមការងារ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនតាមការចាំបាច់។ គណៈកម្មការជំនាញនិង/ឬក្រុមការងាររបស់ **ផ.ក.អ.** ត្រូវបង្កើតដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៧ .-**

គណៈកម្មការជំនាញនិង/ឬក្រុមការងារ អាចអញ្ជើញប្រធានស្ថាប័នឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ ពិគ្រោះយោបល់ ឬចូលរួមបំពេញការងារផ្សេងៗតាមការចាំបាច់។

**មាត្រា៨ .-**

**ផ.ក.អ.** មានលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋាន **ផ.ក.អ.** ដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធាន សមាជិក ទីប្រឹក្សា មន្ត្រីជំនាញ និងបុគ្គលិកបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

**មាត្រា៩ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ផ.ក.អ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ប្រភពធនធានរបស់ ផ.ក.អ.

**មាត្រា១០ .-**

ប្រភពធនធានសម្រាប់ទ្រទ្រង់ **ផ.ក.អ.** មានថវិកាជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

អាណត្តិរបស់ **ផ.ក.អ.** ត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ត្រូវបានបញ្ចប់។

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២៤

នស/រកត.១១២៤.១៤១៥

(ហត្ថលេខា)

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

(ហត្ថលេខា)

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

៥- ឯកឧត្តម **អ៊ិត រ៉ាឌី** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៦- ឯកឧត្តម **ឃ្លង់ ឆ្លាម** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៧- លោកជំទាវ **ម៉ុនីញ ម៉ុណ្ណារី** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៨- ឯកឧត្តម **ម៉េង ម៉ុនធឿន** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៩- ឯកឧត្តម **សេង ម៉ុនឃាង** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
១០- ឯកឧត្តម **អ៊ីវ ម៉ុរិទ្ធ** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
១១- ឯកឧត្តម **ស្រ៊ា រតនៈ** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**មាត្រា៣** : ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣៧៤៤.៤៤១១.១៤៣៦

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២៤*